ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន
MINISTRY OF INFORMATION
លេខ ១៥៥ ព.ម

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១០

## រដ្ឋមន្ត្រីក្រសួងព័ត៌មាន

ជំរាបមក

លោកតំណាងអង្គការ-សមាគមខ្មែរកម្ពុជាក្រោមនៅកម្ពុជា

**កម្មវត្ថុ** : ករណីស្នើសុំម៉ោងវិទ្យុជាតិ ផ្សាយអំពីខ្មែរកម្ពុជាក្រោម។
**យោង** : លិខិតចុះថ្ងៃទី ០៧ ខែមករា ឆ្នាំ២០១០ របស់លោក។

តបតាមកម្មវត្ថុ និងយោងខាងលើ ក្រសួងព័ត៌មានសូមជំរាបជូនលោកតំណាងអង្គការ -សមាគមខ្មែរកម្ពុជាក្រោមនៅកម្ពុជាជ្រាបថា ចំពោះការស្នើសុំផ្សព្វផ្សាយអំពីប្រពៃណីយ ទំនៀមទំលាប់ វប្បធម៌ អក្សរសាស្ត្រ ភាសា និងពង្សាវតាខ្មែរកម្ពុជាក្រោមនៅតាមស្ថានីយវិទ្យុFM ជាតិ ចំនួន០៧ ស្ថានីយ គឺនៅរាជធានីភ្នំពេញ ខេត្តក្រចេះ កំពង់ចាម ស្វាយរៀង តាកែវ កំពត និងខេត្តព្រះសីហនុ ក្រសួងព័ត៌មានសូមអោយលោកធ្វើការទាក់ទងដោយផ្ទាល់ជាមួយស្ថានីយវិទ្យុជាតិនីមួយៗ ដើម្បីផ្លាស់ប្តូរយោបល់ពីលក្ខណៈបច្ចេកទេសនៃការផលិតកម្មវិធីដែលត្រូវផ្សព្វផ្សាយ។

អាស្រ័យដូចបានជំរាបជូនខាងលើ សូមលោកតំណាងចាត់ចែងដំណើរការតាមការគួរ។

សូមលោកទទួលនូវការរាប់អានអំពីខ្ញុំ។

រដ្ឋមន្ត្រី

ខៀវ កាញារីទ្ធ

**ចំលងជូន**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- សាលាខេត្តក្រចេះ កំពង់ចាម ស្វាយរៀង តាកែវ កំពត ព្រះសីហនុ និងរាជធានីភ្នំពេញ "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានសោតទស្សន៍ នៃអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍
- មន្ទីរព័ត៌មានខេត្តក្រចេះ កំពង់ចាម ស្វាយរៀង តាកែវ កំពត ព្រះសីហនុ និងរាជធានីភ្នំពេញ "ដើម្បីអនុវត្ត"
- ឯកសារ